ក្រសួងមហាផ្ទៃ

# សៀវភៅណែនាំសម្រាប់យុវជន ស្ដីពី



# ការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់

ព.ស.២៥៦៧

អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ
ឧបត្ថម្ភបោះពុម្ពដោយយូនីសេហ្វ

ឆ្នាំ២០២៣

# អារម្ភកថា

យោងតាមរបាយការណ៍ស្តីពីយុវជនពិភពលោកក្នុងឆ្នាំ២០២០ ចំណែកនៃចំនួនយុវជនដែលមានអាយុពី១៥ដល់២៤ឆ្នាំ ធៀបនឹងចំនួនប្រជាជនសរុបក្នុងពិភពលោកមានប្រមាណ១,២ប៊ីលានដែលស្មើនឹង១៦ភាគរយនៃចំនួនប្រជាជនសរុប។ ប្រសិនបើអាយុរបស់យុវជនត្រូវបានគិតច្រើនជាងអាយុ២៤ឆ្នាំ(តាមការកំណត់របស់ប្រទេសនីមួយៗ) នោះចំនួននៃយុវជននឹងមានកាន់តែច្រើនជាងនេះ។ តួលេខនេះបានបង្ហាញថាយុវជន(យុវជននិងយុវតី) គឺជាកម្លាំងចលករនិងជាធនធានមនុស្សយ៉ាងសំខាន់ដែលជះឥទ្ធិពលនៅក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោកនិយាយជារួម និងជះឥទ្ធិពលក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់បណ្តាប្រទេសនីមួយៗ និយាយដោយឡែក។ សកម្មភាពរបស់យុវជនបាននាំមកនូវគំនិត យោបល់ និងនវានុវត្តន៍ ក្នុងការរួមចំណែកដល់កិច្ចអភិវឌ្ឍក្នុងសហគមន៍និងប្រទេសជាតិ តាមរយៈការបញ្ចេញទស្សនៈលើបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន នយោបាយ និងកិច្ចការសង្គមផ្សេងទៀត។ដូច្នេះសំឡេងឬទស្សនៈរបស់យុវជនមានសារៈសំខាន់ដែលពាក់ព័ន្ធទៅនឹងការសម្រេចចិត្តរបស់អ្នកដឹកនាំទាំងនៅពេលបច្ចុប្បន្ននិងអនាគត។

ដោយឡែកចំពោះប្រទេសកម្ពុជា យោងតាមទិន្នន័យជំរឿនទូទៅប្រជាជននៅឆ្នាំ២០១៩ ប្រទេសកម្ពុជាមានចំនួនយុវជន(យុវជននិងយុវតី)អាយុក្រោម៣០ឆ្នាំប្រមាណ៥៧ភាគរយ។ បើធៀបនឹងបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាមានចំនួនយុវជនធៀបនឹងប្រជាជនសរុបធំជាងគេ។ តួលេខនេះក៏បានបង្ហាញផងដែរ ថាយុវជននៅក្នុងប្រទេសកម្ពុជា គឺជាធនធានដែលមានសក្តានុពលនៅក្នុងការបន្តនិរន្តរភាពនិងអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ទាំងនៅបច្ចុប្បន្ននិងអនាគត សម្រាប់ប្រទេសកម្ពុជា។

ដើម្បីលើកកម្ពស់យុវជនកម្ពុជាក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅឆ្នាំ២០១១។ គោលនយោបាយជាតិនេះបានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើន ដើម្បីលើកកម្ពស់និងគាំទ្រដល់យុវជនកម្ពុជា ជាពិសេសយុទ្ធសាស្ត្របង្កើនការចូលរួមរបស់យុវជនដែលរួមមាន៖១)-បង្កលក្ខណៈងាយស្រួលឱ្យយុវជនចូលរួមបានពេញលេញក្នុងសហគមន៍មូលដ្ឋាននិងស្ថាប័ននានា ២)-ជំរុញយន្តការជាផ្លូវការឱ្យយុវជនចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយនឹងសមាគម អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ៣)-ជំរុញឱ្យមានតំណាងយុវជននៅក្នុងគណៈកម្មាធិការឬក្រុមប្រឹក្សាថ្នាក់ជាតិឬថ្នាក់ក្រោមជាតិ និងធានាការធ្វើសមាហរណកម្មពួកគេទៅក្នុងដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ ៤)-គាំទ្រឱ្យមានសំឡេងយុវជននៅក្នុងដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាផលប្រយោជន៍របស់យុវជន។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តកន្លងទៅនេះ យើងបានសង្កេតឃើញថាការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតនៅឡើយ ជាពិសេសការចូលរួមយុវជនក្នុងការរៀបចំនិង

ការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។ ផ្អែកលើមូលដ្ឋាននេះ ក្រុមការងារអគ្គនាយកដ្ឋានរដ្ឋបាល តាមរយៈគម្រោងលើកកម្ពស់វិស័យសេវាសង្គមដែលគាំទ្រដោយយូនីសេហ្វ បានសិក្សាលើឯកសារបច្ចេកទេសដែលកំពុងអនុវត្ត និងបានដកស្រង់បទពិសោធពាក់ព័ន្ធនឹងការចូលរួមរបស់យុវជនក្នុងការងារអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបានរៀបចំសៀវភៅណែនាំសម្រាប់យុវជនស្តីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។

សៀវភៅណែនាំនេះ គឺជាចំណេះដឹងនិងជាឯកសារជំនួយស្មារតីសម្រាប់យុវជនឬតំណាងយុវជនកម្ពុជាក្នុងការឈ្វេងយល់អំពីដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំនិងការអនុម័តគម្រោងថវិកានៃរដ្ឋបាលឃុំ សង្កាត់ និងសិទ្ធិរបស់ខ្លួននៅក្នុងការចូលរួមដំណើរការខាងលើនេះ។ ខ្លឹមសារនៃសៀវភៅណែនាំនេះមានលក្ខណៈសង្ខេបដែលបានផ្តោតតែទៅលើយុវជននិងយុវតីជាមួយនឹងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ប៉ុណ្ណោះ។ ទោះយ៉ាងណាក៏ដោយ សៀវភៅណែនាំនេះក៏ជាបច្ច័យដ៏សំខាន់មួយក្នុងការលើកកម្ពស់និងការយកចិត្តទុកដាក់ចំពោះយុវជនទាំងពីរភេទដែលជាធនធានបន្តវេន និងមានសក្តានុពលនៅក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ជាមួយគ្នានេះ ក្រសួងមហាផ្ទៃសង្ឃឹមថាសៀវភៅណែនាំសម្រាប់យុវជនស្តីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ នឹងមានការចូលរួមយោបល់ពីអ្នកពាក់ព័ន្ធថែមទៀត ក្នុងការកែលម្អសៀវភៅណែនាំនេះឱ្យកាន់តែប្រសើរឡើងតាមពេលវេលាសមស្រប៕

ថ្ងៃ.................ខែ............. ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ..............ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកានុក្រម

## ផ្នែកទី១៖សេចក្តីផ្តើម


១.១-សនិទានភាព ... ៩

១.២-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ ... ១០

១.៣-គោលបំណង ... ១១

១.៤-ការប្រើប្រាស់សៀវភៅណែនាំ ... ១២


## ផ្នែកទី២៖សិទ្ធិចូលរួមរបស់យុវជន


២.១-វាក្យសព្ទសំខាន់ៗ ... ១៥

២.២-សិទ្ធិចូលរួមរបស់យុវជន ... ១៥

២.២.១-ការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាន ... ១៦

២.២.២-របៀបនៃការចូលរួមរបស់យុវជន ... ១៧

២.៣-គោលការណ៍នៃការចូលរួមរបស់យុវជន ... ១៧


## ផ្នែកទី៣៖ការយល់ដឹងអំពីរដ្ឋបាលឃុំ សង្កាត់


៣.១-រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់ ... ១៩

៣.១.១-ក្រុមប្រឹក្សាឃុំ សង្កាត់ ... ១៩

៣.១.២.-គណៈកម្មាធិការនានានៃរដ្ឋបាលឃុំ សង្កាត់ ... ២០

៣.១.៣-ភូមិ ... ២១

៣.២-តួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ ... ២២

៣.៣-ការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ... ២៣

៣.៣.១-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ... ២៣

៣.៣.២-កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ... ២៣

៣.៤-ការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់ ... ២៤

## ផ្នែកទី៤៖ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការ អភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់


៤.១-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ..... ២៧

៤.២-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ..... ២៩

៤.៣-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ..... ៣១

៤.៣.១-ការត្រៀមមុនការចូលរួមក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាសង្ខេបឃុំ សង្កាត់ ..... ៣១

៤.៣.២-ការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ ..... ៣២

៤.៣.៣-ការអនុម័តនិងការផ្សព្វផ្សាយគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ..... ៣២

៤.៤-វិធីសាស្រ្តប្រមូលព័ត៏មានរបស់យុវជន ..... ៣៣

៤.៤.១-ការរៀបចំកិច្ចប្រជុំ ..... ៣៣

៤.៤.២-ការស្ទង់មតិ ..... ៣៥

៤.៤.៣-ការពិភាក្សាជាមួយនឹងក្រុមយុវជនគោលដៅជាក់លាក់ ..... ៣៧


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ អំពីជំហានសង្ខេបស្តីពីដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ..... ៤២

ឧបសម្ព័ន្ធទី២ អំពីទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ ..... ៤៣

ឧបសម្ព័ន្ធទី៣ អំពីតារាងបញ្ហានិងដំណោះស្រាយ ..... ៤៤


# ផ្នែកទី១



# សេចក្ដីផ្ដើម





## ១.១-សនិទានភាព

តាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ រដ្ឋបាលឃុំ សង្កាត់ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានតួនាទីបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់ ហើយត្រូវមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋាននានា។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីនិងភារកិច្ចបម្រើការងារមូលដ្ឋានក្នុងកិច្ចការសេវាសាធារណៈជូនប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ លើការងារសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ បរិស្ថាននិងធនធានធម្មជាតិ និងការផ្ដល់សេវាសាធារណៈនានា សំដៅជំរុញលើកកម្ពស់សុខុមាលភាពនិងជីវភាពប្រជាជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម នៅឃុំ សង្កាត់។ ក្នុងការអនុវត្តតួនាទីនិងភារកិច្ចទាំងនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានកាតព្វកិច្ចរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ សម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍឃុំ សង្កាត់។

តាមរយៈប្រកាសរវាងក្រសួងមហាផ្ទៃនិងក្រសួងផែនការលេខ០៨០ ផ.ក លេខ០៧៤ ផ.ក និងលេខ០៧៣ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ដែលបានដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងប្រកាសលេខ០១៤៩ ផ.ក.ប្រក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ ដែលបានដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងកសាងផែនការទាំងនេះឱ្យបានទាន់ពេលវេលាកំណត់ និងតាមនីតិវិធីក្នុងជំហានៗនីមួយៗ។ ការរៀបចំផែនការនេះត្រូវមានជាតុសំខាន់ៗពាក់ព័ន្ធនឹងការប្រមូលតម្រូវការនានាពីប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំនៅតាមភូមិដែលត្រូវមានតំណាងគ្រួសាររបស់ប្រជាពលរដ្ឋចូលរួមយ៉ាងតិច៦០ភាគរយនៃគ្រួសារសរុបក្នុងភូមិនៃឃុំ សង្កាត់។ ប្រជាពលរដ្ឋសំដៅដល់កុមារ យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច មនុស្សចាស់ និងជនងាយរងគ្រោះផ្សេងទៀតនៅក្នុងឃុំ សង្កាត់។

ទន្ទឹមនឹងគ្នានេះ តាមប្រកាសណែនាំលេខ៣៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំនិងការអនុវត្តថវិកាឃុំ សង្កាត់ និងសេចក្ដីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ជារៀងរាល់ឆ្នាំ ដោយត្រូវធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋឬសាធារណជននៅតាមមូលដ្ឋានឃុំ សង្កាត់។

ការចូលរួមរបស់ប្រជាពលរដ្ឋនេះជាកិច្ចការសំខាន់ដែលបានកំណត់ក្នុងគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការចូលរួមនៅក្នុងឯកសារនេះបានផ្ដោតជាសំខាន់ទៅលើវត្តមានរបស់យុវជននិងយុវតីដែលហៅជារួមថាយុវជន នៅក្នុងកិច្ចអភិវឌ្ឍឃុំ សង្កាត់ «**យុវជនជាទំពាំងស្នងឫស្សី**»។ ជាក់ស្ដែង រដ្ឋបាលឃុំ សង្កាត់បានយកចិត្តទុកដាក់និងលើកកម្ពស់យុវជនចូលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ «គ.ក.ន.ក.» ដែលបានកំណត់ក្នុងសេចក្ដីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់។

ជាការណ៍ពិតវត្តមានការចូលរួមរបស់សាធារណជនមានសារៈសំខាន់ក្នុងការពិគ្រោះយោបល់ទាំងនៅតាមភូមិ និងនៅតាមសាលាឃុំ សង្កាត់ ដើម្បីលើកបញ្ហាឬតម្រូវការនានារបស់មូលដ្ឋានផ្ទាល់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកានៃរដ្ឋបាលឃុំ សង្កាត់ប្រចាំឆ្នាំ «**មានការចូលរួមមានការអភិវឌ្ឍ**»។ ក្នុងសកម្មភាពនេះដែរវត្តមានចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍឃុំ សង្កាត់ គឺជាការរៀនសូត្រមួយសម្រាប់យុវជនក្នុងការអភិវឌ្ឍ ហើយក៏ជាកាលានុវត្តភាពក្នុងការរៀបចំខ្លួនរបស់ពួកគេមុនក្លាយជាមនុស្សពេញវ័យ និងជាប្រជាពលរដ្ឋដ៏ល្អក្នុងការបម្រើសកម្មភាពការងារសេវាសាធារណៈ នៅក្នុងសង្គមជាតិ។

ក្នុងការអនុវត្តជាក់ស្ដែង ការចូលរួមរបស់យុវជននេះហាក់បីស្ថិតក្នុងកម្រិតណាមួយអាស្រ័យទៅលើអន្តរប្បច្ច័យជាច្រើន ដូចជាចំណេះដឹងរបស់យុវជនអំពីដំណើរការរៀបចំផែនការនិងថវិកា តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយយុវជនក៏ពុំទាន់យល់ច្បាស់អំពីសិទ្ធិចូលរួមរបស់ខ្លួនក្នុងនាមជាប្រជាពលរដ្ឋនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចនានា។ លើសពីនេះ ការចូលរួមរបស់យុវជនក៏មានឧបសគ្គខ្លះពាក់ព័ន្ធនឹងកត្តាសេដ្ឋកិច្ច ពេលវេលា អាណាព្យាបាល សន្តិសុខ និងកត្តាសង្គម ព្រមទាំងពុំទាន់មានភាពសកម្មក្នុងការលើកទឹកចិត្តនិងគាំពារពីអង្គភាពឬស្ថាប័នពាក់ព័ន្ធឱ្យបានខ្លាំងក្លា ទៅដល់អត្ថប្រយោជន៍របស់យុវជនក្នុងចូលរួមការអភិវឌ្ឍឃុំ សង្កាត់ផងដែរ។

## ១.២-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ

សៀវភៅណែនាំសម្រាប់យុវជនស្ដីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ហៅកាត់ថាសៀវភៅណែនាំសម្រាប់យុវជនស្ដីពី«ច.យ.ផ.ថ.» ជាសៀវភៅណែនាំបច្ចេកទេសដែលផ្ដោតទៅលើសិទ្ធិរបស់យុវជនក្នុងដំណើរការចូលរួមរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់នៅក្នុងទិដ្ឋភាពនៃក្របខណ្ឌគតិយុត្តដែលមានស្រាប់ជាធរមាន ដូចជា៖

- គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០១១
- គោលនយោបាយរបស់រាជរដ្ឋាភិបាលស្ដីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤
- សៀវភៅណែនាំបច្ចេកទេសស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤
- ប្រកាសអន្តរក្រសួងលេខ០៨០ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ០៧៤ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ប្រកាសអន្តរក្រសួងលេខ០៧៣ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់
- ប្រកាសអន្តរក្រសួងលេខ០១៤៩ ផ.ក ប្រ.ក ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- សេចក្ដីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- សេចក្ដីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- លិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។

## ១.៣-គោលបំណង

សៀវភៅណែនាំសម្រាប់យុវជនស្ដីពី«ច.យ.ផ.ថ.»មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិនៃការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ តាមរយៈដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់។

## ១.៤-ការប្រើប្រាស់សៀវភៅណែនាំ

សៀវភៅណែនាំសម្រាប់យុវជនស្តីពី«ច.យ.ផ.ថ.»ជាឯកសារជំនួយសម្រាប់យុវជនឈ្វេងយល់និងប្រើប្រាស់ដើម្បីចូលរួមក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ។

សៀវភៅណែនាំនេះមានបីផ្នែកសំខាន់ៗរួមមានទីមួយអំពីសេចក្តីផ្តើមដែលបានផ្តោតលើ សនិទានភាព មូលដ្ឋានគតិយុត្ត គោលបំណង និងការប្រើប្រាស់សៀវភៅណែនាំ ទីពីរអំពីសិទ្ធិនៃការចូលរួមរបស់យុវជនដែលផ្តោតលើសិទ្ធិរបស់យុវជន និងគោលការណ៍នៃការចូលរួមរបស់យុវជន ទីបីអំពីការយល់ដឹងអំពីរដ្ឋបាលឃុំ សង្កាត់ដែលបានផ្តោតលើក្រុមប្រឹក្សាឃុំ សង្កាត់ ភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការនានា និងរចនាសម្ព័ន្ធនានានៃរដ្ឋបាលឃុំ សង្កាត់ និងទីបួនអំពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ដែលបានផ្តោតលើដំណើរការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងវិធីសាស្ត្រនៃការប្រមូលព័ត៌មានរបស់យុវជន ។



# ផ្នែកទី២

# សិទ្ធិចូលរួមរបស់យុវជន





## ២.១-វាក្យសព្ទសំខាន់ៗ

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសិក្សានិងឈ្វេងយល់នូវវាក្យសព្ទសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការចូលរួមរបស់យុវជនដូចខាងក្រោម៖

**យុវជន៖**សំដៅលើបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ១៥ឆ្នាំដល់៣០ឆ្នាំ នៅលីវឬរៀបការហើយ(តាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០១១)។

**ការចូលរួមរបស់យុវជន៖**សំដៅលើការចូលរួមដែលមានចរិតលក្ខណៈជាបុគ្គល ឬជាក្រុមដោយផ្ទាល់ឬដោយប្រយោល ដើម្បីបញ្ចេញទស្សនៈ មតិ ឬយោបល់ផ្ទាល់របស់ខ្លួន ក្នុងការធ្វើសំណូមពរ ការឆ្លើយតប និងការសម្រេចចិត្តពាក់ព័ន្ធនឹងកិច្ចការនានានៃដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំនិងអនុម័តគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់។

**សមធម៌៖**សំដៅលើក្រុមឬយុវជនទាំងអស់ដែលត្រូវបានផ្តល់ឱកាសស្មើគ្នាឬដូចគ្នា នៅក្នុងការចូលរួមបញ្ចេញមតិឬយោបល់ ដើម្បីលើកឡើងនូវតម្រូវការសម្រាប់ដាក់ជូនរដ្ឋបាលឃុំ សង្កាត់ និងអាចចូលរួមចំណែកតាមដាននូវការអនុវត្តកិច្ចការនានាក្នុងការអភិវឌ្ឍឃុំ សង្កាត់។

**តម្លាភាព៖**សំដៅលើការបើកចំហព័ត៌មានទូលំទូលាយដល់ការចូលរួមរបស់យុវជន តាមរយៈការផ្សព្វផ្សាយជាសាធារណៈ ការសម្រេចចិត្ត និងការអនុវត្តនានា ក្នុងដំណើរការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងគម្រោងថវិកាឃុំ សង្កាត់។

## ២.២-សិទ្ធិចូលរួមរបស់យុវជន

មាត្រា៣៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យនិងការដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ ក្នុងន័យនេះ យុវជនដែលជាប្រជាពលរដ្ឋមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីរួមចំណែកអភិវឌ្ឍមូលដ្ឋាន។

## ២.២.១-ការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាន

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូប ( ស្ត្រី បុរស ចាស់ ក្មេង និងជនងាយរងគ្រោះ ) មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់ និងដំណើរការអភិវឌ្ឍមូលដ្ឋាន ដូចជាការបញ្ចេញមតិនិងការរួមចំណែកតាមមធ្យោបាយផ្សេងៗ។ ក្នុងនាមជាប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្ដីត្រូវការនិងផលប្រយោជន៍របស់ខ្លួន តាមរយៈនីតិវិធីនិងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាននិងសេចក្ដីណែនាំនានា។ ការចូលរួមអភិវឌ្ឍមូលដ្ឋានមិនមែនគ្រាន់តែជាសិទ្ធិរបស់មនុស្សពេញវ័យ តែជាសិទ្ធិរបស់យុវជនផងដែរ។ ការងារអភិវឌ្ឍមូលដ្ឋានក្នុងពេលនេះនឹងផ្ដោតយកចិត្តទុកដាក់លើការចូលរួមរបស់យុវជនដែលជាការរួមចំណែកដ៏សំខាន់ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យស្វែងយល់ពីសេចក្ដីត្រូវការរបស់យុវជន ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនានារបស់យុវជនក្នុងការអភិវឌ្ឍឃុំ សង្កាត់។

ការចូលរួមរបស់យុវជនក្នុងកិច្ចអភិវឌ្ឍមូលដ្ឋាន គឺជាទំនាក់ទំនងដ៏សំខាន់រវាងយុវជននិងក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវទទួលបាននិងផ្ដល់ផលប្រយោជន៍ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងយុវជន ក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដូចខាងក្រោម៖

| ក្រុមប្រឹក្សាឃុំ សង្កាត់ | យុវជន |
| --- | --- |
| • ទទួលបានធាតុចូលនិងចំណេះដឹងថ្មីៗសំខាន់ៗពីយុវជនសម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត<br>• ពង្រឹងឆន្ទៈនិងទំនុកចិត្តកាន់តែរឹងមាំថែមទៀតក្នុងការបំពេញការងារបម្រើប្រជាពលរដ្ឋ<br>• បង្កើនភាពស្និទ្ធស្នាលនិងទំនាក់ទំនងល្អជាមួយនឹងយុវជន<br>• អាចរៀបចំគម្រោងអភិវឌ្ឍ និងផ្ដល់សេវាសាធារណៈដែលឆ្លើយតបនឹងតម្រូវការជាក់លាក់របស់យុវជនប្រសើរជាងមុន។ | • បង្កើនចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រកបដោយភាពវិជ្ជមានក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់<br>• ទទួលបានឱកាសចូលរួមក្នុងការអភិវឌ្ឍគ្រួសារ សហគមន៍ និងសង្គមជាតិ<br>• មានឱកាសចូលរួមក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍមូលដ្ឋាន<br>• រួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការឆ្លើយតបក្នុងការផ្ដល់សេវាសាធារណៈ។ |



ផ្នែកទី២
អំពីសិទ្ធិចូលរួមរបស់យុវជន

## ២.២.២-របៀបនៃការចូលរួមរបស់យុវជន

ការចូលរួមរបស់យុវជន គឺជាសកម្មភាពដែលយុវជនរួមគ្នាគិត ពិចារណា និងផ្ដល់មតិនិងយោបល់ព្រមទាំងការធ្វើសេចក្ដីសម្រេច ក្នុងការអភិវឌ្ឍឃុំ សង្កាត់។ ជាទូទៅ ការចូលរួមរបស់យុវជននេះអាចធ្វើឡើងដោយផ្ទាល់ និងតាមរយៈអ្នកតំណាង នៅក្នុងការអភិវឌ្ឍឃុំ សង្កាត់។

- ការចូលរួមដោយផ្ទាល់ គឺជាការចូលរួមរបស់យុវជនដោយខ្លួនឯងក្នុងការផ្ដល់ធាតុចូលនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តនោះ ។
- ការចូលរួមតាមរយៈអ្នកតំណាង គឺជាការចូលរួមដោយតំណាងរបស់យុវជនដើម្បីផ្ដល់មតិនិងយោបល់ដែលជាធាតុចូលក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្ត នៅក្នុងការអភិវឌ្ឍឃុំ សង្កាត់។

## ២.៣-គោលការណ៍នៃការចូលរួមរបស់យុវជន

**ការស្មគ្រចិត្ត៖** យុវជនផ្ទាល់ខ្លួនចូលរួមដោយការពេញចិត្ត មិនមានការបង្ខិតបង្ខំ ហើយយុវជនអាចជ្រើសរើសដោយសេរីថាចូលរួមឬមិនចូលរួម ព្រមទាំងអាចដកខ្លួនពីដំណើរការបានគ្រប់ពេលវេលា នៅក្នុងការអភិវឌ្ឍមូលដ្ឋាន

**ទទួលបានព័ត៌មានគ្រប់គ្រាន់៖** យុវជនមានសិទ្ធិស្នើសុំព័ត៌មានលម្អិតអំពីដំណើរការឬសកម្មភាពដែលខ្លួនមានបំណងចូលរួម និងស្វែងរកព័ត៌មានពាក់ព័ន្ធដើម្បីជាជំនួយក្នុងការពិភាក្សាឬអនុវត្តសកម្មភាពនានាក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

**វិន័យ និងសណ្ដាប់ធ្នាប់៖** យុវជនត្រូវគោរពនិងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងនីតិវិធីនិងបទបញ្ញត្តិពាក់ព័ន្ធ នៅពេលចូលរួមប្រជុំពិគ្រោះយោបល់ ឬអនុវត្តសកម្មភាពក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

**សុជីវធម៌៖** យុវជនត្រូវគោរពមតិនិងយោបល់របស់អ្នកចូលរួមទាំងអស់ ដោយមិននិយាយកាត់ ឬសើចចំអក ឬសកម្មភាពមានះយកឈ្នះចាញ់។ យុវជនត្រូវប្រើពាក្យគួរសមនិងប្រកាន់ខ្ជាប់នូវការគោរពចំពោះអ្នកចូលរួមនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវមានសណ្ដាប់ធ្នាប់ល្អក្នុងការចូលរួម។

# ផ្នែកទី៣

## ការយល់ដឹងអំពីរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដែលកើតឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់(សកល សេរី ត្រឹមត្រូវ និងយុត្តិធម៌ ចំពោះ និងសម្ងាត់)។ ក្នុងដំណើរការគ្រប់គ្រងនិងដឹកនាំរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួន។ រដ្ឋបាលឃុំ សង្កាត់ដែលដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីសំខាន់ គឺបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងជាភ្នាក់ងារតំណាងរដ្ឋក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មអំណាចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋាន។



## ៣.១-រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗកើតឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់ ដែលមានសមាជិកពី៥ទៅ១១រូប ផ្អែកទៅតាមកត្តាភូមិសាស្ត្រនិងប្រជាសាស្ត្រនៃឃុំ សង្កាត់នីមួយៗ ។ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ព័ន្ធដឹកនាំ ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ គណៈកម្មាធិការនានា និងស្មៀនឃុំ សង្កាត់ ព្រមទាំងភូមិមួយចំនួន ។

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានស្មៀនឃុំ សង្កាត់មួយនាក់ ។ ស្មៀនឃុំ សង្កាត់ជាមន្ត្រីក្របខណ្ឌនៃក្រសួងមហាផ្ទៃ ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ និងទទួលខុសត្រូវចំពោះក្រសួងមហាផ្ទៃ ក្នុងការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ ស្របតាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ ស្មៀនឃុំ សង្កាត់មានភារកិច្ចជួយរដ្ឋបាលឃុំ សង្កាត់លើកិច្ចការសំខាន់ៗ ដូចជាកិច្ចការចាត់ចែងលិខិតនិងឯកសារនានា ថែរក្សានិងទុកដាក់លិខិតនិងឯកសារ ពិនិត្យលើភាពត្រឹមត្រូវលើលិខិតនានាជូនមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ និងទំនាក់ទំនងការងារ នៅរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងទទួលភារកិច្ចកិច្ចការផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានពាក់ព័ន្ធ ។

### ៣.១.១-ក្រុមប្រឹក្សាឃុំ សង្កាត់

ឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតឡើងដោយការបោះឆ្នោតផ្ទាល់ដោយប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិប្រាំឆ្នាំជាតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ដែលមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានភារកិច្ចជាចម្បងក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋសំដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការងារអភិវឌ្ឍឃុំ សង្កាត់ ។ ក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំថវិកានៃរដ្ឋបាលឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន១នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់ ។

មេឃុំ ចៅសង្កាត់មានជំទប់ទី១ឬចៅសង្កាត់រងទី១ និងជំទប់ទី២ឬចៅសង្កាត់រងទី២ ជាជំនួយការក្នុងការដឹកនាំនិងគ្រប់គ្រងការងាររដ្ឋបាលឃុំ សង្កាត់ ។

## ៣.១.២.-គណៈកម្មាធិការនានានៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានគណៈកម្មាធិការនិងឬគណៈកម្មការមួយចំនួនសម្រាប់ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់។ គណៈកម្មាធិការនេះអាចត្រូវចាត់តាំងដោយមេឃុំ ចៅសង្កាត់ ដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិនៃការអនុវត្តការងារជាក់លាក់ណាមួយ ដូចជាគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់«គ.ផ.ថ» គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់«គ.ក.ន.ក.» គណៈកម្មការលទ្ធកម្ម និងគណៈកម្មការនានាតាមការចាំបាច់ និងតាមការកំណត់ដោយលិខិតបទដ្ឋាន។

### ក-គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់

គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ ហៅកាត់ថា«គ.ផ.ថ.»។ «គ.ផ.ថ.» ត្រូវបានបង្កើតឡើងដោយមេឃុំ ចៅសង្កាត់។ «គ.ផ.ថ.» មានតួនាទីនិងការទទួលខុសត្រូវចំពោះមេឃុំ ចៅសង្កាត់ និងមានភារកិច្ចរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ។

### ខ-គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ហៅកាត់ថា«គ.ក.ន.ក.»។«គ.ក.ន.ក.» ត្រូវបានបង្កើតឡើងដោយមេឃុំ ចៅសង្កាត់ ដែលមានតួនាទីជួយក្រុមប្រឹក្សាឃុំ សង្កាត់ផ្តោតទៅលើការងារសេវាសង្គម នៅថ្នាក់ឃុំ សង្កាត់ តាមប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់។ «គ.ក.ន.ក.» មានសមាសភាពជាសមាជិកមកពីអង្គភាពមួយចំនួននៅក្នុងឃុំ សង្កាត់រួមមានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា មណ្ឌលសុខភាពឬប៉ុស្តិ៍សុខភាព ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជន និងអង្គភាពពាក់ព័ន្ធ។ ចំពោះសមាជិក «គ.ក.ន.ក.»ជាតំណាងយុវជនត្រូវជ្រើសរើសដោយមេឃុំ ចៅសង្កាត់ តាមសេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់។





## ៣.១.៣-ភូមិ

ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានជាឃុំឬសង្កាត់មួយ។

ភូមិនីមួយៗគ្រប់គ្រងដោយមេភូមិ១នាក់ អមដោយអនុប្រធានភូមិ១នាក់ និងសមាជិកភូមិ១នាក់ជាជំនួយការ។

មេភូមិម្នាក់សម្រាប់ភូមិនីមួយៗត្រូវបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់សាមី។ អនុប្រធានភូមិនិងសមាជិកភូមិត្រូវអនុម័តជ្រើសរើសដោយកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់សាមី។

មេភូមិ គឺជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្លងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិមានជំនួយការរបស់ខ្លួនចំនួន២នាក់(ម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ)។

មេភូមិមានភារកិច្ចជួយក្រុមប្រឹក្សាឃុំ សង្កាត់លើកិច្ចការនានាក្នុងភូមិរបស់ខ្លួនស្របតាមលិខិតបទដ្ឋានជាធរមាន។ ក្នុងកិច្ចការអភិវឌ្ឍភូមិ មេភូមិមានភារកិច្ចផ្តល់យោបល់និងលើកបញ្ហាឬតម្រូវការរបស់ប្រជាពលរដ្ឋឬរបស់ភូមិសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ។ លើសពីនេះ មេភូមិត្រូវអនុវត្តកិច្ចការនានាដែលសម្រេចនិងប្រគល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការផ្សព្វផ្សាយព័ត៌មានទៅដល់ប្រជាពលរដ្ឋ ការធ្វើសេចក្តីរាយការណ៍កិច្ចការភូមិទៅរដ្ឋបាលឃុំ សង្កាត់ និងកិច្ចការផ្សេងទៀត។

### រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់



## ៣.២-តួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់

| តួនាទីបម្រើកិច្ចការ | តួនាទីជាភ្នាក់ងារតំណាងរដ្ឋ |
| --- | --- |
| • ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ។<br>• រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ។<br>• លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។<br>• ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។<br>• ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ។<br>• សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក។<br>• បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ | • រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។<br>• ដើម្បីអនុវត្តតួនាទីនេះអាជ្ញាធររដ្ឋធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនឹងការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយសម្ភារៈ ថវិកាសម្រាប់អនុវត្ត។ |

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។ រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យព្រៃឈើ ប្រៃសណីយ៍ និងទូរគមនាគមន៍ ការពារជាតិ សន្តិសុខជាតិ រូបិយវត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។



ផ្នែកទី៣
អំពីការយល់ដឹងអំពីរដ្ឋបាលឃុំ សង្កាត់

## ៣.៣-ការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

### ៣.៣.១-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់សម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំដែលមានចរិតជាទស្សនៈអភិវឌ្ឍន៍រួមរបស់រដ្ឋបាលឃុំ សង្កាត់ ដែលបានរៀបចំឡើងដោយមានការចូលរួមពីប្រជាពលរដ្ឋនិងពីភាគីពាក់ព័ន្ធនៅឃុំ សង្កាត់។

ជារួម កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ គឺជារបៀបវារៈឬកម្មវិធីជាក់ស្តែងដែលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចង់សម្រេចបានក្នុងអាណត្តិខ្លួនសម្រាប់បង្ហាញពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងចំពោះរាជរដ្ឋាភិបាល។

**ជំហាននៃដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

- **ជំហានទី១** ការវិភាគស្ថានភាពនិងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់
- **ជំហានទី២** ការរៀបចំនិងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- **ជំហានទី៣** ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

### ៣.៣.២-កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ត្រូវបានរៀបចំឡើងតាមរយៈការធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅជាគម្រោង ឬសកម្មភាព ឬសេវាកម្ម និងមានចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈនិងកិច្ចអភិវឌ្ឍឃុំ សង្កាត់សម្រាប់រយៈពេលបីឆ្នាំ។ គម្រោងឬសកម្មភាពគម្រោង គឺជាគម្រោងឬសកម្មភាពត្រូវចំណាយមូលនិធិដោយមានពេលចាប់ផ្តើម និងពេលបញ្ចប់ច្បាស់លាស់ ក្នុងការបង្កើតទ្រព្យសម្បត្តិសាធារណៈ ( ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងអរូបវន្ត ) និងសេវានានា ដែលឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

### ជំហាននៃដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

| | |
|---|---|
| ជំហានទី១ | ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋាន |
| ជំហានទី២ | ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ |
| ជំហានទី៣ | ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិល |

## ៣.៤-ការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់

អនុលោមតាមមាត្រា៧៣និងមាត្រា៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវមានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយឃុំ សង្កាត់ត្រូវបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រង តាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន។ ថវិកាឃុំ សង្កាត់ គឺជាលិខិតគតិយុត្តដែលគ្រោងនិងអនុញ្ញាតចំណូល និងចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ។ ប្រភពចំណូលឃុំ សង្កាត់សំខាន់ៗមាន៣ផ្នែក៖

- ចំណូលផ្ទាល់៖ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ
- ចំណូលពីមូលនិធិឃុំ សង្កាត់៖ចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ទៅឱ្យឃុំ សង្កាត់នីមួយៗ ដែលក្នុងនោះមានចំណែកសម្រាប់ចំណាយផ្នែករដ្ឋបាល និងចំណាយផ្នែកអភិវឌ្ឍន៍ឃុំ សង្កាត់
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ៖ចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ជំនួសមុខឱ្យក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា។

ក្រៅពីចំណូលខាងលើ រដ្ឋបាលឃុំ សង្កាត់មានចំណូលផ្សេងៗទៀត គឺចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។ រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងធនធានហិរញ្ញវត្ថុថវិកានិងទ្រព្យសម្បត្តិទាំងនេះយ៉ាងហ្មត់ចត់ ដើម្បីធានាថាការប្រើប្រាស់ធនធានរបស់រដ្ឋបាលឃុំ សង្កាត់ឱ្យបានត្រឹមត្រូវ មានតម្លាភាព សន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់។ ឆ្នាំថវិការបស់ឃុំ សង្កាត់ចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។





នៅក្នុងដំណើរការនៃការរៀបចំនិងការអនុម័តថវិកាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវធានាឱ្យមានការចូលរួមពីសាធារណជន និងយកចិត្តទុកដាក់ចំពោះយុវជននិងឬក្រុមយុវជននៅមូលដ្ឋានឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវធានាអនុវត្តកិច្ចការមួយចំនួនគឺ៖

- ការទទួលបានមតិសាធារណជន និងការពិគ្រោះយោបល់ ត្រូវបានប្រព្រឹត្តទៅក្នុងដំណើរការនៃការរៀបចំនិងការអនុម័តថវិកាឃុំ សង្កាត់
- យុវជននិងឬក្រុមយុវជនត្រូវបានទទួលការលើកទឹកចិត្ត និងការអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងដំណើរការរៀបចំថវិកាឃុំ សង្កាត់។

ក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់បានរៀបចំប្រតិទិននៃដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ ស្របតាមសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។ ប្រតិទិននេះ ជាជំហានសង្ខេបស្តីពីដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ សម្រាប់យុវជនឬក្រុមយុវជនត្រូវដឹងអំពីពេលវេលាឬកាលបរិច្ឆេទនៃជំហាននីមួយៗ ក្នុងដំណើការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប៉ុណ្ណោះ ដូចមានជាឧទាហរណ៍ក្នុងឧបសម្ព័ន្ធទី១នៃសៀវភៅណែនាំនេះផងដែរ។ ដូច្នេះ យុវជនត្រូវស្វែងរកប្រតិទិនឬជំហានសង្ខេបនេះដែលបានរៀបចំដោយមេឃុំ ចៅសង្កាត់ ដើម្បីត្រៀមខ្លួនចូលរួមក្នុងជំហាននីមួយៗនៃដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ។ ជំហានសង្ខេបស្តីពីដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ មានព័ត៌មានអំពីរយៈពេលនិងកាលបរិច្ឆេទបិទផ្សព្វផ្សាយទម្រង់ថវិកាសង្ខេបឃុំ សង្កាត់ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងសាធារណជន កិច្ចប្រជុំអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងការធ្វើអនុលោមភាពលើគម្រោងថវិកាឃុំ សង្កាត់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ក្នុងដំណើរការនៃការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់នេះដែរ «គ.ផ.ថ.» បានរៀបចំសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំ ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។ សេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំមានព័ត៌មានសំខាន់ៗ សម្រាប់ពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនៅឃុំ សង្កាត់។ សេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំនេះមានព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងថវិកា និងសកម្មភាពឬគម្រោង (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងព័ត៌មានផ្សេងទៀតរបស់រដ្ឋបាលឃុំ សង្កាត់) ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃសៀវភៅណែនាំនេះផងដែរ។

# ផ្នែកទី៤

# ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់

ក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវកសាងនិងរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់សម្រាប់រយៈពេលប្រាំឆ្នាំ។ នៅរៀងរាល់ឆ្នាំ រដ្ឋបាលឃុំ សង្កាត់ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកសាងនិងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ។ រដ្ឋបាលឃុំ សង្កាត់ត្រូវប្រមូលបញ្ហាឬតម្រូវការនានារបស់ប្រជាពលរដ្ឋសម្រាប់រៀបចំផែនការឃុំ សង្កាត់ និងថវិកាឃុំ សង្កាត់ទាំងនេះ តាមរយៈការចូលរួមពីប្រជាពលរដ្ឋ ឬសាធារណជន នៅមូលដ្ឋានឃុំ សង្កាត់។

ការចូលរួមរបស់ប្រជាពលរដ្ឋសំដៅការចូលរួមរបស់ជនគ្រប់រូបដូចជាបុរស ស្ត្រី យុវជននិងយុវតី ជនមានពិការភាព ជនជាតិដើមភាគតិចជាដើម។ ប៉ុន្តែ សៀវភៅណែនាំនេះគ្រាន់តែផ្តោតយកចិត្តទុកដាក់ជំរុញនិងលើកកម្ពស់ចំពោះយុវជនឱ្យចូលរួមក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ស្របតាមនីតិវិធីដែលមានជាធរមាន។ ដូច្នេះ យុវជនឬតំណាងយុវជនអាចចូលរួមក្នុងជំហាននីមួយៗស្របតាមនីតិវិធីជាធរមាន ហើយក៏អាចអនុវត្តវិធីសាស្ត្រសាមញ្ញៗសម្រាប់ចូលរួមក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ដូចខាងក្រោម៖

## ៤.១-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់



ដើម្បីចូលរួមក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ យុវជននិងក្រុមយុវជនត្រៀមខ្លួនជាមុន ដោយស្វែងរកព័ត៌មានមុនការចាប់ផ្តើមជំហានទាំងបី មានដូចខាងក្រោម៖

- យុវជននិងតំណាងយុវជនត្រូវស្វែងរកប្រតិទិននិងព័ត៌មានពាក់ព័ន្ធនឹងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ នៅលើក្តារព័ត៌មានឃុំ សង្កាត់ ឬសាកសួរព័ត៌មានពីស្មៀនឃុំ សង្កាត់ ឬអ្នកពាក់ព័ន្ធនានា
- តំណាងយុវជនត្រូវផ្សព្វផ្សាយដល់សមាជិកក្រុមយុវជន និងប្រមូលព័ត៌មានអំពីតម្រូវការ កង្វល់ និងមតិឬយោបល់ពីយុវជនក្នុងសហគមន៍ ដើម្បីត្រៀមជាធាតុចូលនៅក្នុងជំហានទី១ តាមវិធីសាស្ត្រដូចមានក្នុងចំណុច«៤.៤»នៃសៀវភៅណែនាំនេះ ឬអាចប្រើប្រាស់មធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត។

បន្ទាប់ពីទទួលបានព័ត៌មានឬប្រតិទិននៃដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ យុវជននិងតំណាងយុវជនមានសិទ្ធិចូលរួមក្នុងជំហានទាំងបីនៃដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដូចខាងក្រោម៖

### ជំហានទី១៖
### ការវិភាគស្ថានភាពនិងការកំណត់តម្រូវលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

យុវជនអាចចូលរួមក្នុងជំហានទីមួយនៃដំណើរការវិភាគស្ថានភាពនិងកំណត់តម្រូវការនានាដែល«គ.ផ.ថ»រៀបចំការប្រជុំពិគ្រោះយោបល់នៅតាមភូមិ ដើម្បីប្រមូលតម្រូវការនានារបស់មូលដ្ឋាន គឺ៖

- យុវជនត្រូវចូលរួមដោយផ្ទាល់ក្នុងការប្រជុំ ដើម្បីលើកពីតម្រូវការរបស់ខ្លួន
- តំណាងយុវជនត្រូវលើកតម្រូវការ និងកង្វល់របស់យុវជន ដែលប្រមូលបានពីការពិគ្រោះយោបល់ជាមួយនឹងសមាជិកយុវជននៅក្នុងសហគមន៍
- បន្ទាប់ពីចូលរួមកិច្ចប្រជុំនេះ តំណាងយុវជនត្រូវចែករំលែកព័ត៌មាន ឬសេចក្តីសម្រេចពីអង្គប្រជុំប្រសិនជាមាន ទៅដល់សមាជិករបស់ខ្លួននៅក្នុងសហគមន៍ តាមវិធីសាស្ត្រដូចមានរៀបរាប់ក្នុងចំណុច «**៤.៤**» នៃសៀវភៅណែនាំនេះ ឬអាចប្រើប្រាស់មធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត។

### ជំហានទី២៖
### ការរៀបចំនិងការចងក្រងលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- តំណាងយុវជនត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដើម្បីផ្តល់យោបល់លើបទបង្ហាញស្តីពីក្របខណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់





- បន្ទាប់ពីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់នេះ តំណាងយុវជនត្រូវចែករំលែកព័ត៌មានឬសេចក្តីសម្រេចពីអង្គប្រជុំ( ប្រសិនជាមាន ) ទៅដល់សមាជិករបស់ខ្លួននៅក្នុងសហគមន៍ តាមមធ្យោបាយសមស្របដែលអាចធ្វើបាន ឬវិធីសាស្ត្រដូចមានក្នុងចំណុច«៤.៤.១-» នៃសៀវភៅណែនាំនេះ។

### ជំហានទី៣៖
### ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- យុវជន និងតំណាងយុវជនស្នើសុំថតចម្លងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ឬថតចម្លងត្រឹមតែក្របខណ្ឌអភិវឌ្ឍន៍ឃុំ សង្កាត់«តារាង២.១» និងក្របខណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំ«តារាង២.២»នៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលបានអនុម័ត
- តំណាងយុវជនត្រូវផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ «តារាង២.១» និងតារាង២.២ ទៅដល់សមាជិករបស់ខ្លួននៅក្នុងសហគមន៍ តាមមធ្យោបាយសមស្របដែលអាចធ្វើបាន ឬវិធីសាស្ត្រដូចក្នុងចំណុច «៤.៤.១» នៃសៀវភៅណែនាំនេះ។

## ៤.២-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ដើម្បីចូលរួមក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ យុវជនត្រៀមខ្លួនជាមុន ដោយស្វែងរកព័ត៌មានមុនការចាប់ផ្តើមជំហានទាំងបី មានដូចខាងក្រោម៖

- យុវជននិងតំណាងយុវជនត្រូវស្វែងរកប្រតិទិន និងព័ត៌មានពាក់ព័ន្ធនឹងដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- តំណាងយុវជនត្រូវផ្សព្វផ្សាយពីប្រតិទិននៃដំណើរការរៀបចំប្រមូលព័ត៌មានអំពីតម្រូវការនិងមតិឬយោបល់ពីយុវជនក្នុងមូលដ្ឋានឃុំ សង្កាត់ ដើម្បីជាធាតុចូលនៅក្នុងជំហានទី១
- តំណាងយុវជនអាចប្រើប្រាស់វិធីសាស្ត្រនានាក្នុងចំណុច «**៤.៤**» នៃសៀវភៅណែនាំនេះ ដើម្បីផ្សព្វផ្សាយ និងប្រមូលទិន្នន័យពីយុវជនក្នុងឃុំ សង្កាត់។

បន្ទាប់ពីទទួលបានព័ត៌មានឬប្រតិទិននៃដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ យុវជននិងតំណាងយុវជនមានសិទ្ធិចូលរួមក្នុងជំហានទាំងបីឬជំហានណាមួយទៅតាមនីតិវិធីនៃដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលមានស្រាប់ ដូចខាងក្រោម៖

## ជំហានទី១៖
## ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់រៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ក្នុងជំហានទីមួយនៃដំណើរការរៀបចំការប្រជុំពិគ្រោះយោបល់នៅតាមភូមិ ដើម្បីប្រមូលតម្រូវការរបស់មូលដ្ឋាន «គ.ផ.ថ.»ត្រូវយកចិត្តទុកដាក់ឱ្យមានការចូលរួមពីយុវជនក្នុងកម្មភាព ដូចជា៖

- យុវជនត្រូវចូលរួមដោយផ្ទាល់ក្នុងការប្រជុំ ដើម្បីលើកពីតម្រូវការរបស់យុវជន
- តំណាងយុវជនត្រូវលើកនូវតម្រូវការនិងកង្វល់របស់យុវជនដែលប្រមូលបានពីការពិគ្រោះយោបល់ជាមួយនឹងសមាជិកយុវជន និងយុវជនដទៃទៀតនៅក្នុងសហគមន៍
- បន្ទាប់ពីចូលរួមប្រជុំខាងលើ តំណាងយុវជនត្រូវរាយការណ៍អំពីព័ត៌មាន ឬសេចក្តីសម្រេចពីអង្គប្រជុំ( ប្រសិនជាមាន )ទៅសមាជិកយុវជន និងយុវជនដទៃទៀតនៅក្នុងសហគមន៍ តាមវិធីសាស្ត្រដូចមានរៀបរាប់ក្នុងចំណុច «**៤.៤**» នៃសៀវភៅណែនាំនេះ ឬមធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត។

នៅក្នុងជំហានទី១នេះដែរ យុវជននិងឬតំណាងយុវជនអាចចូលរួមស្តាប់នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តលើសេចក្តីព្រាងបញ្ជីគម្រោងអាទិភាពដែលប្រើប្រាស់ថវិកាឃុំ សង្កាត់ ហើយក៏អាចផ្សព្វផ្សាយនូវសេចក្តីសម្រេចឬលទ្ធផលនៃកិច្ចប្រជុំនេះ ទៅសមាជិកយុវជននិងឬតំណាងយុវជននៅក្នុងសហគមន៍ តាមវិធីសាស្ត្រក្នុងចំណុច «**៤.៤**» នៃសៀវភៅណែនាំនេះ ឬមធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមសមស្របផ្សេងទៀត។







## ជំហានទី២៖
## ការរៀបចំនិងការចងក្រងលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ជំហានទី២នេះ ជាជំហាននៃការអនុវត្តបច្ចេកទេសរដ្ឋបាលក្នុងការរៀបចំបញ្ជីគម្រោងប្រកបដោយសង្គតិភាព និងសុខដុមនីយកម្មនៃគម្រោងទាំងឡាយរបស់ស្ថាប័ន អង្គភាព សមាគម និងអង្គការមិនមែនរដ្ឋាភិបាលឬសង្គមស៊ីវិល និងវិស័យឯកជន ក្នុងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធនៅក្នុងដែនសមត្ថកិច្ចនៃក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងជំហានទី២នេះ យុវជននិងឬតំណាងត្រូវស្វែងរកព័ត៌មានតាមរយៈមេភូមិ និងអ្នកពាក់ព័ន្ធ ឬតាមការបិទផ្សាយនានា ដើម្បីចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

## ជំហានទី៣៖
## ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយលើកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

តំណាងយុវជនត្រូវផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់( តារាង២.២ គម្រោងសកម្មភាពកំពុងដំណើរការ និងតារាង២.៣ គម្រោងឬសកម្មភាពវិនិយោគឃុំ សង្កាត់ដែលមានថវិកាគាំទ្រ ) ទៅកាន់សមាជិកយុវជនរបស់ខ្លួន និងយុវជនដទៃទៀតក្នុងមូលដ្ឋាន។

## ៤.៣-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

ផ្អែកតាមប្រតិទិនដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំដែលបានផ្សព្វផ្សាយដោយរដ្ឋបាលឃុំ សង្កាត់ យុវជនឬតំណាងយុវជនអាចចូលរួមក្នុងជំហាននីមួយៗ ហើយក៏អាចអនុវត្តវិធីសាស្ត្រសាមញ្ញៗសម្រាប់ប្រមូលធាតុចូលពីក្រុមយុវជនក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ផងដែរ។

### ៤.៣.១-ការត្រៀមមុនការចូលរួមក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាសង្ខេបឃុំ សង្កាត់

យុវជននិងតំណាងយុវជនត្រូវស្វែងរកព័ត៌មានអំពីប្រតិទិននៃដំណើរការរៀបចំនិងអនុម័តគម្រោងថវិកា និងសេចក្តីព្រាងគម្រោងថវិកាសង្ខេបរបស់រដ្ឋបាលឃុំ សង្កាត់។ យុវជននិងតំណាងយុវជនអាចស្វែងរក

ព័ត៌មានទាំងនេះនៅតាមទីតាំងបិទផ្សាយសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ នៅតាមសាលាឃុំ សង្កាត់ ភូមិនីមួយៗ ទីផ្សារ សាលាធទាន សាលាបុណ្យ សាលារៀន មណ្ឌលសុខភាព វត្តអារាម និង ទីប្រជុំជននានា។

តំណាងយុវជនអាចរៀបចំការពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ ជាមួយនឹងសមាជិករបស់ខ្លួននិងយុវជនទូទៅក្នុងសហគមន៍ឃុំ សង្កាត់ តាមវិធីសាស្ត្រដូចមានក្នុងចំណុច«**៤.៤**» នៃសៀវភៅណែនាំនេះ ឬមធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត ដើម្បីស្វែងយល់ពីកម្រិតនៃការឆ្លើយតបនឹងសេចក្តីព្រាងគម្រោងថវិកាឃុំ សង្កាត់ចំពោះតម្រូវការរបស់យុវជន។

### ៤.៣.២-ការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់

យុវជននិងតំណាងយុវជនត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំ ដើម្បីផ្តល់ធាតុចូលសំខាន់ៗទៅលើសេចក្តីព្រាងទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំ។

បន្ទាប់ពីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់នេះ តំណាងយុវជនត្រូវចែករំលែកព័ត៌មាននិងលទ្ធផលនៃការពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបនេះ ទៅដល់សមាជិកយុវជនរបស់ខ្លួននៅក្នុងសហគមន៍ឃុំ សង្កាត់ តាមវិធីសាស្ត្រដូចមានក្នុងចំណុច «**៤.៤.១**» នៃសៀវភៅណែនាំនេះ ឬមធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងៗ។

### ៤.៣.៣-ការអនុម័តនិងការផ្សព្វផ្សាយគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

យុវជននិងតំណាងយុវជនអាចចូលរួមសង្កេតនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីការអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ នៅតាមសាលាឃុំ សង្កាត់។

បន្ទាប់ពីចូលរួមស្តាប់កិច្ចប្រជុំស្តីពីការអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំនៅសាលាឃុំ សង្កាត់នេះ តំណាងយុវជនត្រូវចែករំលែកព័ត៌មាននៃគម្រោងថវិកាឃុំ សង្កាត់ដែលក្រុមប្រឹក្សាបានអនុម័តទៅសមាជិករបស់ខ្លួននៅក្នុងសហគមន៍ឃុំ សង្កាត់ តាមវិធីសាស្ត្រដូចមានក្នុងចំណុច«**៤.៤**»នៃសៀវភៅណែនាំនេះ ឬមធ្យោបាយសមស្របដែលអាចធ្វើបានតាមរយៈតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត។





## ៤.៤-វិធីសាស្ត្រប្រមូលព័ត៌មានរបស់យុវជន

តំណាងយុវជនមានតួនាទីសំខាន់ក្នុងការលើកកម្ពស់នូវការចូលរួមរបស់យុវជន តាមរយៈសកម្មភាពក្នុងការដើរតួនាទីជាស្ពានតភ្ជាប់រវាងអាជ្ញាធរមូលដ្ឋាននិងយុវជនទូទៅក្នុងសហគមន៍។ យុវជនអាចមកពីប្រភពយុវជនផ្សេងគ្នានៅក្នុងសហគមន៍មូលដ្ឋាន ដូចជាយុវជនមានពិការភាព យុវជនមកពីក្រុមជនជាតិដើមភាគតិច យុវជនបោះបង់ចោលការសិក្សា ឬយុវជនចំណាកស្រុកទៅក្រៅប្រទេស ។ល។ យុវជនទាំងនេះពិតជាមានតម្រូវការ បញ្ហា និងសំណូមពរខុសៗគ្នាពិតមែន តែស្ថិតក្នុងគោលបំណងរួមបម្រើផលប្រយោជន៍យុវជនក្នុងការចូលរួមអភិវឌ្ឍឃុំ សង្កាត់ប្រកបដោយសុខដុមរមនា។ ដូច្នេះ ការប្រមូលព័ត៌មាននិងការទទួលបានព័ត៌មានពីស្ថានភាពទូទៅ ឬពីបញ្ហាជាក់លាក់ណាមួយរបស់យុវជនឬក្រុមយុវជន គឺជាអន្តរប្បច្ច័យអាចរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

ក្រៅពីការចូលរួមដោយពិគ្រោះយោបល់ដោយផ្ទាល់នៅតាមភូមិ យុវជនឬក្រុមយុវជនអាចប្រមូល និងទទួលបានមតិ យោបល់ និងព័ត៌មាននានាពីយុវជនឬក្រុមយុវជននានាក្នុងមូលដ្ឋានឃុំ សង្កាត់ តាមវិធីសាស្ត្រផ្សេងទៀត សម្រាប់ជាធាតុចូលក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។ តំណាងយុវជនអាចប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោម៖

- កិច្ចប្រជុំ
- ការស្ទង់មតិ
- ការពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់។

តំណាងយុវជនឬក្រុមយុវជន អាចអនុវត្តវិធីសាស្ត្រមួយចំនួនឬវិធីសាស្ត្រណាមួយនៃវិធីសាស្ត្រទាំងបី ដើម្បីប្រមូលមតិ យោបល់ ឬតម្រូវការនិងបញ្ហានានារបស់យុវជនសម្រាប់ជាធាតុចូលក្នុងការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។ វិធីសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

### ៤.៤.១-ការរៀបចំកិច្ចប្រជុំ

តំណាងយុវជនអាចរៀបចំកិច្ចប្រជុំក្នុងគោលបំណងមួយឬច្រើន ដូចខាងក្រោម៖

- ស្តាប់យោបល់ និងពិភាក្សាជាមួយនឹងយុវជនអំពីស្ថានភាព និងតម្រូវការរបស់ពួកគេ
- ពិភាក្សាជាមួយនឹងយុវជនអំពីបញ្ហាជាក់លាក់ណាមួយ
- អាចបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល ឬគម្រោងថវិកានៃរដ្ឋបាលឃុំ សង្កាត់
- ផ្សព្វផ្សាយនិងចែករំលែកព័ត៌មានដល់យុវជនក្នុងឃុំ សង្កាត់ អំពីសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ជំហានអនុវត្ត

### ក-មុនពេលកិច្ចប្រជុំ

ដើម្បីឱ្យកិច្ចប្រជុំដំណើរការប្រកបដោយប្រសិទ្ធភាព តំណាងយុវជនគួរអនុវត្តនូវកិច្ចការមួយចំនួនដូចជា៖

- កំណត់របៀបវារៈសម្រាប់ការប្រជុំ
- ជ្រើសរើសនិងកំណត់ទីកន្លែងនិងពេលវេលាដែលត្រូវរៀបចំកិច្ចប្រជុំ ដោយពិចារណាទៅលើភាពងាយស្រួលក្នុងការធ្វើដំណើរ និងពេលវេលាសមស្របដែលមិនធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់យុវជន
- កំណត់ព័ត៌មានដែលខ្លួននឹងផ្តល់ជូននៅពេលប្រជុំ ឧទាហរណ៍៖បទបង្ហាញពីផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ឬគម្រោងថវិកាឃុំ សង្កាត់
- រៀបចំឯកសារ និងបទបង្ហាញដែលចាំបាច់
- ជ្រើសរើសអ្នកមានបទពិសោធធ្វើជាអ្នកសម្របសម្រួលកិច្ចប្រជុំ ឬអាចធ្វើជាអ្នកសម្របសម្រួលកិច្ចប្រជុំដោយយុវជនខ្លួនឯងផ្ទាល់
- រៀបចំវិធីសាស្ត្រដែលនឹងត្រូវប្រើប្រាស់ ដើម្បីធានាថាយុវជនគ្រប់រូបអាចមានឱកាសចូលរួមបញ្ចេញមតិនិងយោបល់ ដូចជាបែងចែកយុវជនជាក្រុមពិភាក្សា អាចជាក្រុមចម្រុះ ឬក្រុមតាមភេទបុរស ឬក្រុមតាមភេទស្ត្រី ឬក្រុមតាមអាយុ។ល។
- ផ្សព្វផ្សាយអំពីព័ត៌មានពាក់ព័ន្ធកិច្ចប្រជុំឱ្យបានទូលំទូលាយតាមរយៈមធ្យោបាយសមស្របនានា ដូចជាតេឡេក្រាម ហ្វេសប៊ុក ឬបណ្តាញសង្គមផ្សេងទៀត។

### ខ-កំលុងពេលកិច្ចប្រជុំ

ពេលដំណើរការកិច្ចប្រជុំ តំណាងយុវជនត្រូវអនុវត្តសកម្មភាព ដូចជា៖

- តំណាងយុវជនបើកកិច្ចប្រជុំ និងបង្ហាញគោលបំណងនិងរបៀបវារៈនៃកិច្ចប្រជុំ
- តំណាងយុវជន ឬអ្នកសម្របសម្រួលព្យាយាមលើកទឹកចិត្តយុវជនឱ្យពិភាក្សាយ៉ាងសកម្ម ដោយបំផុសសំណួរ និងផ្តល់ឱកាសដល់យុវជនឱ្យចូលរួមចែករំលែកមតិឬយោបល់របស់ពួកគេ
- តំណាងយុវជន ឬអ្នកសម្របសម្រួលគ្រាន់តែស្តាប់ ហើយមិនត្រូវព្យាយាមនិយាយកាត់អ្នកចូលរួមឡើយ លើកលែងតែការពិភាក្សាក្រៅប្រធានបទ
- អ្នកកត់ត្រាត្រូវកត់មតិឬយោបល់ សំណូមពរ និងអនុសាសន៍ទាំងអស់របស់អ្នកចូលរួម។





### គ-ក្រោយពេលកិច្ចប្រជុំ

តំណាងយុវជនយកលទ្ធផលនៃកិច្ចប្រជុំជាមួយនឹងសមាជិកក្រុមរបស់ខ្លួនសម្រាប់ជាមូលដ្ឋានក្នុងការផ្តល់យោបល់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់។

## ៤.៤.២-ការស្ទង់មតិ

**ការស្ទង់មតិ៖**ជាវិធីសាស្ត្រមួយនៃការប្រមូលព័ត៌មាន មតិឬយោបល់ និងសំណូមពរពីយុវជនទូទៅ ឬជាក់លាក់ណាមួយនៅក្នុងសហគមន៍។ ការស្ទង់មតិអាចជាលក្ខណៈទូទៅ និងលក្ខណៈសំណាក មានដូចខាងក្រោម៖

**ការស្ទង់មតិលើយុវជនទូទៅ៖**ការស្ទង់មតិលើយុវជនអនុវត្តចំពោះយុវជនដែលទទួលផលប៉ះពាល់ ទាំងអស់តាមរយៈការសម្ភាស។ ការធ្វើបែបនេះអាចដំណើរការទៅបាន ប្រសិនបើយុវជនដែលត្រូវធ្វើសម្ភាសន៍មានចំនួនកំណត់។ ឧទាហរណ៍៖ តំណាងយុវជនចង់ដឹងថា តើយុវជនចង់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ជួយអ្វីខ្លះដល់ពួកគេ? ដូច្នេះ ត្រូវធ្វើការស្ទង់មតិមួយនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យទាំងអស់។

**ការស្ទង់មតិជាតំណាង(សំណាក)៖**ប្រសិនបើតំណាងយុវជនចង់បានទស្សនៈរួមរបស់យុវជនភាគច្រើននៅឃុំ សង្កាត់ នោះតំណាងយុវជនគួរធ្វើការស្ទង់មតិជាតំណាងដោយត្រូវជ្រើសរើសយុវជនមួយចំនួនតិចសម្រាប់ធ្វើជាតំណាងឱ្យយុវជនទាំងអស់សម្រាប់ធ្វើការស្ទង់មតិ។

**ឧទាហរណ៍៖**តំណាងយុវជនចង់ដឹងថា តើយុវជនពេញចិត្តនឹងការងារផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយនៅឃុំដែរឬទេ? តំណាងយុវជនគួរធ្វើការស្ទង់មតិជាតំណាងដោយជ្រើសរើសយុវជនមួយក្រុមចំនួន១០០នាក់សម្រាប់សម្ភាស។ចំនួនដែលជ្រើសរើសនេះតំណាងឱ្យយុវជនទាំងអស់ក្នុងឃុំ។

ការស្ទង់មតិអាចប្រើប្រាស់ទម្រង់ជាលាយលក្ខណ៍អក្សរ ឬការស្ទង់មតិផ្ទាល់មាត់។ ការស្ទង់មតិជាលាយលក្ខណ៍អក្សរត្រូវរៀបចំជាបញ្ជីសំណួរ ហើយត្រូវចែកដោយផ្ទាល់នៅក្នុងចំណោមក្រុមគោលដៅ ឬដាក់នៅកន្លែងងាយស្រួលស្វែងរក។ អ្នកផ្តល់ចម្លើយត្រូវបំពេញបញ្ជីសំណួរ ហើយយកបញ្ជីសំណួរនិងចម្លើយទៅដាក់នៅកន្លែងប្រមូលយកបញ្ជីសំណួរវិញស្របតាមការណែនាំ។

ការស្ទង់មតិផ្ទាល់មាត់ ជាការជួបសម្ភាសតាមរយៈការជួបមុខគ្នាផ្ទាល់ ឬតាមរយៈទូរសព្ទដោយ ផ្អែកទៅលើបញ្ជីសំណួរដែលបានរៀបចំជាស្រេច។ ការស្ទង់មតិអាចប្រើប្រាស់សំណួរពីរប្រភេទ គឺសំណួរបិទ

និងសំណួរបើក ដូចជា៖

- **សំណួរបិទ៖** ជាប្រភេទសំណួរដែលផ្តល់នូវចម្លើយសម្រាប់ជ្រើសរើស ហើយអ្នកឆ្លើយត្រូវជ្រើសរើសយកជម្រើសណាមួយ ឧទាហរណ៍៖សំណួរសួរថា«តើការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានសារៈសំខាន់ដែរឬទេ ?» ចម្លើយត្រូវគូសមានពីរគឺ៖☐ បាទឬចាស ☐ ទេ
- **សំណួរបើក៖** ជាប្រភេទសំណួរមិនកំណត់ចម្លើយថាបាទឬចាសឬទេឡើយ។ចម្លើយមិនកំណត់ទេ អ្នកផ្តល់ចម្លើយអាចចែករំលែកមតិឬយោបល់របស់ខ្លួនជាលក្ខណៈបុគ្គល។ ការវិភាគបញ្ជីសំណួរបើកត្រូវចំណាយពេលច្រើន អ្នកផ្តល់ចម្លើយមានឱកាសបកស្រាយចម្លើយរបស់ខ្លួនបានទូលំទូលាយ។ឧទាហរណ៍៖តើអ្នកយល់យ៉ាងណាពីការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ?។

**ឧទាហរណ៍៖** កម្រងសំណួរស្តីពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

**១. តើអ្នកធ្លាប់ចូលរួមប្រជុំពិគ្រោះយោបល់នៅតាមភូមិដែរឬទេ?**

☐ ក-ធ្លាប់( ប្រសិនជាធ្លាប់ សូមបន្តទៅសំណួរទី២ )
☐ ខ-មិនធ្លាប់( ប្រសិនជាមិនធ្លាប់ សូមរំលងទៅសំណួរទី៣ )។

**២. តើអ្នកធ្លាប់បានលើកពីបញ្ហា ឬតម្រូវការនានាក្នុងពេលប្រជុំនៅតាមភូមិដែរឬទេ?**

☐ ក-បាទឬចាស ☐ ខ.ទេ

**៣. ហេតុអ្វីបានជាអ្នកមិនធ្លាប់ចូលរួមប្រជុំនៅតាមភូមិ?**

..........................................................................................................
..........................................................................................................

**៤. ក្នុងចំណោមបញ្ហាខាងក្រោម តើបញ្ហាណាខ្លះដែលអ្នកគិតថាជាបញ្ហាចម្បងដែលយុវជនកំពុងជួបប្រឈមនៅក្នុងសហគមន៍? (អាចគូសយកជម្រើសច្រើនជាងមួយ)**

☐ ក-គ្រឿងញៀន ☐ខ-ក្មេងទំនើង

☐ គ-ផ្លូវថ្នល់ ☐ ឃ-យុវជនបោះបង់ចោលការសិក្សា





☐ ង-ទឹកស្អាតនិងអនាម័យ ☐ ច-អំពើហិង្សាក្នុងគ្រួសារ ☐ ឆ-បញ្ហាយុវជនចំណាកស្រុក

☐ ជ-បញ្ហាផ្សេងៗ ... ( បញ្ជាក់ )

**៥. តើអ្នកគិតថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើអ្វីខ្លះ ដើម្បីជំរុញឱ្យយុវជនចូលរួមបានច្រើនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់?**

..........................................................................................................
..........................................................................................................។

## ៤.៤.៣-ការពិភាក្សាជាមួយនឹងក្រុមយុវជនគោលដៅជាក់លាក់

ការពិភាក្សាជាមួយនឹងក្រុមយុវជនគោលដៅជាក់លាក់មានសារៈសំខាន់ណាស់ នៅពេលតំណាងយុវជនចង់ប្រមូលព័ត៌មាន ឬស្វែងយល់ពីតម្រូវការនិងកង្វល់នានាពីក្រុមគោលដៅជាក់លាក់ ដូចជាយុវជនមានពិការភាព យុវជនមកពីក្រុមជនជាតិដើមភាគតិច យុវជនបោះបង់ចោលការសិក្សា ឬយុវជនចំណាកស្រុកក្រៅប្រទេស។ ដើម្បីឱ្យដំណើរការពិភាក្សាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តំណាងយុវជនគួរអនុវត្ត ដូចតទៅ៖

### ជំហានអនុវត្ត

### ក-មុនពេលកិច្ចពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់

- កំណត់ប្រធានបទសម្រាប់ការពិភាក្សា
- កំណត់ចំនួនអ្នកចូលរួមនៅក្នុងការពិភាក្សា។ជាការប្រសើរ ការពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់ មិនគួរមានចំនួនអ្នកចូលរួមលើសពី១២នាក់ឡើយ
- ជ្រើសរើសទីកន្លែងងាយស្រួលរក និងពេលវេលាសមស្របសម្រាប់រៀបចំការពិភាក្សា
- រៀបចំកម្មវិធីឬរបៀបវារៈដែលអាចដាក់បញ្ចូលនូវចំណុចមួយចំនួន ដូចខាងក្រោម៖
  - + បង្ហាញគោលបំណង
  - + ប្រធានបទពិភាក្សា
  - + ការណែនាំឱ្យស្គាល់អ្នកចូលរួម
  - + ការបង្ហាញឯកសារដែលពាក់ព័ន្ធនានា
  - + សំណួរសំខាន់ៗ ដែលត្រូវសួរដល់អ្នកចូលរួម

- ជ្រើសរើសយកអ្នកសម្របសម្រួលដែលមានបទពិសោធ ឬអាចជាតំណាងយុវជនខ្លួនឯងផ្ទាល់ ដើម្បីដឹកនាំការពិភាក្សាឱ្យមានភាពរស់រវើក ហើយអ្នកចូលរួមទាំងអស់អាចចូលរួមមតិនិងយោបល់។

## ខ-កំលុងពេលកិច្ចពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់

- តំណាងយុវជនបើកការពិភាក្សា និងប្រាប់គោលបំណងនៃកិច្ចប្រជុំ
- អ្នកសម្របសម្រួលចាប់ផ្តើមការពិភាក្សា ដោយសួរសំណួរអ្នកចូលរួម
- អ្នកចូលរួមចែករំលែកមតិឬយោបល់របស់ខ្លួន និងផ្តល់អនុសាសន៍
- អ្នកសម្របសម្រួលកត់ត្រាលទ្ធផលនៃការពិភាក្សា អនុសាសន៍របស់អ្នកចូលរួម និងការព្រមព្រៀងប្រសិនជាមាន។

## គ-ក្រោយពេលកិច្ចពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់

តំណាងយុវជនយកលទ្ធផលនៃកិច្ចប្រជុំជាមួយនឹងសមាជិកក្រុមរបស់ខ្លួនសម្រាប់ជាមូលដ្ឋានក្នុងការផ្តល់យោបល់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់។

!

ការជ្រើសរើសវិធីសាស្ត្រនៃការប្រមូលព័ត៌មានបានសមស្រប គឺអាស្រ័យលើកត្តាមួយចំនួន ដូចជាតើប្រភេទព័ត៌មានបែបណាដែលត្រូវការជាចាំបាច់? តើមានអ្នកណាខ្លះដែលអាចផ្តល់ព័ត៌មានបាន? តើមានការលំបាកបែបណាខ្លះទាក់ទងនឹងពេលវេលា និងថវិកា? និងតើអ្នកណាដែលនឹងប្រើប្រាស់ព័ត៌មានទាំងនេះ?។ បន្ថែមពីនេះ តំណាងយុវជនអាចប្រើប្រាស់វិធីសាស្ត្រលើសពីមួយ ដើម្បីប្រមូលព័ត៌មានលើកិច្ចការណាមួយតាមស្ថានភាព និងតម្រូវការជាក់ស្តែង។

នៅក្នុងវិធីសាស្ត្រនៃការចូលរួមរបស់យុវជន តំណាងយុវជនអាចប្រើប្រាស់ឧទាហរណ៍ខាងក្រោមនេះដើម្បីបំពេញព័ត៌មានពាក់ព័ន្ធនឹងបញ្ហាឬតម្រូវការនិងដំណោះស្រាយរបស់យុវជនសម្រាប់ជាធាតុចូលក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។





## តារាងបញ្ហានិងដំណោះស្រាយ

- ក្រុមយុវជនឈ្មោះ (ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍យុវជនឃុំមង្គល)
- ឃុំ ....(មង្គល).....ស្រុក................. ខេត្ត...............................................
- បញ្ហាប្រឈមនិងដំណោះស្រាយអំពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំមង្គល ឆ្នាំ២០២៣-២០២៥។

| បញ្ហាឬតម្រូវការ | ផលប៉ះពាល់ | សំណូមពរ | ទីតាំង |
|---|---|---|---|
| ការបោះចោលសំរាមពាសវាលពាសកាល | • ដីខូចដីជាតិ<br>• ស្ទះលូ ប្រឡាយទឹក<br>• ប៉ះពាល់ដល់សុខភាពសាធារណជន<br>• គ្មានខ្យល់អាកាសល្អ | • បង្កើតកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ<br>• ផ្សព្វផ្សាយពីវិធីទុកដាក់សំរាមឱ្យបានត្រឹមត្រូវ<br>• ផាកពិន័យបុគ្គលដែលចោលសំរាមគ្មានសណ្តាប់ធ្នាប់ | គ្រប់ភូមិ |
| បញ្ហាក្មេងទំនើង | • បង្កអសន្តិសុខក្នុងសហគមន៍<br>• បង្កគ្រោះថ្នាក់ចរាចរណ៍នៅពេលជិះម៉ូតូប្រដេញវ៉ាយគ្នា | • បង្កើនការល្បាតរាល់យប់<br>• ចាប់ក្មេងទំនើបយកមកអប់រំនិងធ្វើកិច្ចសន្យាថាមិនបង្កអសន្តិសុខ | ភូមិចុងដូង និងភូមិអូរពងមាន់ |
| អំពើហិង្សាក្នុងគ្រួសារ | | • អប់រំពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ<br>• កាត់ទោសជនល្មើសប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ | ភូមិដាន់ដាន ភូមិរំដួង និងភូមិវិច្ឆិកា |

រៀបចំដោយ៖...មាន សិរី

តួនាទី៖តំណាងក្រុមយុវជន

កាលបរិច្ឆេទ៖ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣

វិធីសាស្ត្រខាងលើនេះ មានសារៈសំខាន់សម្រាប់យុវជនឬតំណាងយុវជន ប្រមូលព័ត៌មានអំពីបញ្ហា និងដំណោះស្រាយពីយុវជននិងក្រុមយុវជនក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និង កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដើម្បីងាយស្រួលទទួលបានព័ត៌មានទាំងនេះ តំណាងយុជនប្រើប្រាស់ តារាងបញ្ហានិងដំណោះស្រាយដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី៣នៃសេចក្តីណែនាំនេះ។ តារាងនេះប្រើប្រាស់ សម្រាប់ក្រុមយុវជន និងរៀបចំដោយតំណាងក្រុមយុវជននៅក្នុងមូលដ្ឋានឃុំ សង្កាត់។





# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១អំពីជំហានសង្ខេបស្តីពីដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

### ជំហានសង្ខេប
### ស្តីពីដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ២០....

១)- មេឃុំ ចៅសង្កាត់បំពេញព័ត៌មានក្នុងទម្រង់ថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំសម្រាប់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ

↓

២)-មេឃុំ ចៅសង្កាត់បិទផ្សាយទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ ក្នុងរយៈពេល២សប្តាហ៍មុនកិច្ចប្រជុំពិគ្រោះយោបល់គម្រោងថវិកា( ចាប់ពីថ្ងៃទី....ដល់ថ្ងៃទី...ខែ.....ឆ្នាំ២០...មិនឱ្យហួសថ្ងៃទី**១៥** ខែតុលា )

↓

៣)-គ.ផ.ថ. រៀបចំប្រជុំពិគ្រោះយោបល់គម្រោងថវិកាឃុំ សង្កាត់ជាមួយប្រជាពលរដ្ឋ នៅសាលាឃុំ សង្កាត់ (នៅថ្ងៃទី.....ខែ.......ឆ្នាំ២០......មិនឱ្យហួសថ្ងៃទី២២ ខែតុលា ឬអាចមុនថ្ងៃទី២២ ខែតុលានេះ)

↓

៤)-មេឃុំ ចៅសង្កាត់បិទផ្សាយគម្រោងថវិកាឃុំ សង្កាត់ មុនការអនុម័តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់( ចាប់ពីថ្ងៃទី.. ដល់ថ្ងៃទី....ខែ.....ឆ្នាំ២០..... មិនឱ្យហួសថ្ងៃទី២៩ ខែតុលា)

↓

៥)-មេឃុំ ចៅសង្កាត់អញ្ជើញប្រជាពលរដ្ឋចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីការអនុម័តគម្រោងថវិកាប្រចាំឆ្នាំ នៅសាលាឃុំ សង្កាត់(ចាប់ពីថ្ងៃទី....ដល់ថ្ងៃទី....ខែ....ឆ្នាំ២០....ឱ្យបានមុនថ្ងៃទី៣១ ខែតុលា)

↓

៦)-មេឃុំ ចៅសង្កាត់រៀបចំគម្រោងថវិកាប្រចាំឆ្នាំដាក់ជូនអភិបាលរាជធានី ខេត្តបញ្ជាក់អនុលោមភាពឱ្យបានមុនថ្ងៃទី៥ ខែវិច្ឆិកា

↓

៧)-មេឃុំ ចៅសង្កាត់បិទផ្សព្វផ្សាយគម្រោងថវិកាសង្ខេបឃុំ សង្កាត់ ក្រោយពីការបញ្ជាក់អនុលោមភាពគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

**សម្គាល់៖**ជំហានសង្ខេបនេះត្រូវបានរៀបចំដាស្រេចដោយមេឃុំ ចៅសង្កាត់ តាមសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ មិនតម្រូវឱ្យយុវជននិងក្រុមយុវជនបំពេញឡើយ។



# ឧបសម្ព័ន្ធទី២ អំពីទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់


ទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ ឆ្នាំ២០......

រដ្ឋបាលឃុំ ឬសង្កាត់.................... ក្រុង ស្រុក ឬខណ្ឌ.................... រាជធានី ឬខេត្ត....................

| បរិយាយគម្រោង ឬ សកម្មភាព | ទឹកប្រាក់ជារៀល | ទីតាំងគម្រោងនៅភូមិ | ចំនួនអ្នកទទួលផល |
| --- | --- | --- | --- |
| ចំណូលសរុប | | | |
| ចំណាយសរុប | | | |
| ចំណាយអភិវឌ្ឍន៍សរុប | | | |

**សម្គាល់៖**ទម្រង់គម្រោងថវិកាសង្ខេបនេះត្រូវបានរៀបចំនិងបំពេញព័ត៌មានដោយរដ្ឋបាលឃុំ សង្កាត់ តាមសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។

# ឧបសម្ព័ន្ធទី៣អំពីតារាងបញ្ហានិងដំណោះស្រាយ

## តារាងបញ្ហានិងដំណោះស្រាយ

ក្រុមយុវជនឈ្មោះ .....................................................................................................

ឃុំ សង្កាត់............................ក្រុង ស្រុក ខណ្ឌ........រាជធានី ខេត្ត..............................

បញ្ហានិងដំណោះស្រាយអំពី ..............................................................................

| បញ្ហាឬតម្រូវការ | ផលប៉ះពាល់ | សំណូមពរ | ទីតាំង |
|---|---|---|---|
| | | | |
| | | | |
| | | | |

រៀបចំដោយ ៖..................

តួនាទី ៖............................

កាលបរិច្ឆេទ ៖ថ្ងៃទី..... ខែ..... ឆ្នាំ២០.....

Australian Aid

unicef

for every child